ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១០២
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥

សាលដីកា
លេខ : ១៤៨
ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦

ដែលមានសមាសភាពដូចខាងក្រោម :

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២ - លោក វៀល មួន ជាចៅក្រម
៣ - លោក ស៊ិន ឌឹម ជាចៅក្រម
៤ - លោក ឈឹម ស៊ីផល ជាចៅក្រម
៥ - លោក យស់ សូខឿន ជាចៅក្រមរបាយការណ៍
លោក ឡេង វុធ ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខៈ ១៤៤" ឈ " ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ ៤៤៧ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ សុខ ឃឿន(ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់-ដូរ មានទីលំនៅ ផ្ទះលេខៈ ១៤២ ផ្លូវលេខៈ ១៣៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ អ៊ឹង សារិ " ស " ម្តាយឈ្មោះ រស់ អឿន " ស " ។

មានមេធាវីលោក កែវ យ៉ា ។

និង ចុងចម្លើយឈ្មោះ អ៊ុង សារួន ( ជាម្ចាស់បណ្តឹងសាទុក្ខ )ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់-ដូរ មានទីលំនៅ ភូមិផ្សារសាមគ្គី ឃុំកណ្តោលដុំ ស្រុកប្បារមាន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ អ៊ុង ហ៊ាន " ស " ម្តាយឈ្មោះ ញ៉ែម ផុន " ស " ។

មានមេធាវីលោក នូ ចន្ថា ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីលំនៅដ្ឋាន និង ផ្ទះតាមកិច្ចសន្យា. ទាមទារថ្លៃឈ្នួលផ្ទះ និង សុំឱ្យរុះរើឥវ៉ាន់ចេញពីផ្ទះ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ ៧៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ សុខ ឃឿន និង បណ្តឹងសាទុក្ខលេខៈ ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះ អ៊ុង សារួន និង អ្នកស្រី ទិត្យ ស៊ីណា បានប្តឹង

មិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ១០២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៦-១១-២០០៣ របស់ដើមចោទឈ្មោះ សុខ ឃឿន ថា : ខ្លួនប្តឹងសុំគ្រប់គ្រងដី និង ផ្ទះតាមកិច្ចសន្យាទិញ-លក់ដី និង ផ្ទះ ពីឈ្មោះ អ៊ុង សារុន និង ប្រពន្ធឈ្មោះ ទិត្យ ស៊ីណា ដោយហេតុថា កាលពីថ្ងៃទី០៤-០៣-២០០២ ពីរនាក់ប្តីប្រពន្ធនេះ បានលក់ដី និង ផ្ទះមកឱ្យខ្លួនហើយឈ្មោះទាំងពីរនាក់ប្តីប្រពន្ធនេះ បានធ្វើកិច្ចសន្យាជួលផ្ទះរបស់ខ្លួនវិញ ហើយអ្នកទាំងពីរនេះមិនគោរពតាមកិច្ចសន្យានេះឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខៈ ១៣ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ÷

១ -ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី០៦-១១-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ឱ្យឈ្មោះ អ៊ុង សារុន និង ប្រពន្ធឈ្មោះ ទិត ស៊ីណាត ជញ្ជូនទ្រព្យសម្បត្តិរបស់ខ្លួនចេញពីផ្ទះកើតហេតុនេះ ហើយប្រគល់ផ្ទះ និង ដីឡូតិ៍នៅភូមិផ្សារសាមគ្គី ឃុំករណ្តាលដុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ឱ្យទៅឈ្មោះ សុខ ឃឿន ដើមចោទចាប់តាំងពីថ្ងៃនេះតទៅ តាមមាត្រា៣៤ នៃច្បាប់ស្តីពី កិច្ចសន្យា និង ការទទួលសុខត្រូវក្រៅកិច្ចសន្យា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខៈ ៣៨ ក្រ.ច ចុះថ្ងៃទី២៨-១០-១៩៨៨ ។

៣ - បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛០០ ក្នុងនោះមានពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛០០ និង ចំណាយលើអាជ្ញាធរកណ្តាលចំនួន ៥.០០០ សរុបទាំងអស់ ៧.០០០៛០០ និង ពន្ធសមាមាត្រ១% ។

សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និង បើកផ្លូវឱ្យប្តឹងទាស់ នឹង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី២៩-០៣-២០០៤ របស់ឈ្មោះ អ៊ុង សារុន បានប្តឹងមិនសុខចិត្តនឹងសលក្រមរបស់តុលាការខេត្តកំពង់ស្ពឺត្រង់ចំណុចនៃសេចក្តីទាំងមូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខៈ ៣៣ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ÷

១ - ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ អ៊ុង សារុន ចុះថ្ងៃទី២៩-០៣-២០០៤ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បដិសេធសាលក្រមរដ្ឋប្បវេណីលេខៈ ១៣ ចុះថ្ងៃទី០៤-០៣-២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី២ នៃសាលក្រមចោលជាអសារបង់ ។

៣ - បង្គាប់ឱ្យដើមបណ្តឹងទាស់ឈ្មោះ អ៊ុង សារុន និង ប្រពន្ធឈ្មោះ ទិត្យ ស៊ីណា សងប្រាក់ដើមចំនួន ៣.៦០០ដុល្លា ( បីពាន់ប្រាំមួយរយដុល្លាអាមេរិក ) បន្ថែមលើប្រាក់ដែលឈ្មោះ សុខ ឌឿន បានទទួលចំនួន ៦.៥០០ ដុល្លា ( ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក ) រួចហើយ និង ឱ្យបង់ប្រាក់ការប្រាក់ចំនួន ៦០០ដុល្លា ( ប្រាំមួយរយដុល្លា

អាមេរិក ) សរុប ៤.២០០ដុល្លា ( បួនពាន់ពីររយដុល្លាអាមេរិក ) ឱ្យទៅចុងចម្លើយឈ្មោះ សុខ ឃឿន ចាប់ពីថ្ងៃប្រកាស សាលក្រមនេះតទៅ ។ យោងតាមមាត្រា ៩៦, ៩៧ នៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុស ត្រូវក្រៅកិចសន្យា បើឈ្មោះ អ៊ុង សារួន និង ប្រពន្ធឈ្មោះ ទិត្យ ស៊ីណា ពុំមានប្រាក់សងគ្រប់ចំនួនទេនោះ ត្រូវរឹប អូសផ្ទះ និង ដីឡូតិ៍ ដែលមានទំនាស់នោះលក់ឡាយឡុងដើម្បីធានាសំណងគ្រប់ចំនួនឱ្យទៅចុងចម្លើយឈ្មោះ សុខ ឃឿន ក្នុងករណីរឹងរូសពុំព្រមសងត្រូវចាប់ដាក់គុកបង្ខំរូបរាងកាយក្នុងរឿងរដ្ឋប្បវេណី ។

៤ - បង្គាប់ឱ្យឈ្មោះ អ៊ុង សារួន បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛០០ ក្នុងនោះមានប្រាក់ពន្ធហ្វ៊ីង ប្រាក់ចុះបញ្ជីក្តីចំនួន ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ អ្នករត់ដីកាកោះ ៥.០០០៛០០ សរុប ៧.០០០៛ ដែលឈ្មោះ សុខ ឃឿន បានបង់រួចហើយ និង ឱ្យបង់ពន្ធសមាមាត្រ ១% នៃប្រាក់ជំពាក់ទាំងមូលពេលសាលក្រមនេះចូលជាស្ថាពរ ។

៥ - សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្តនឹងសេចក្តីសំរេចនេះ បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍រយៈពេល២ ខែតាមច្បាប់កំណត់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខៈ ១៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ សុខ ឃឿន បានប្តឹងមិនសុខចិត្តនឹងសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខៈ ១៤៤ " ឈ " ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៤-០៥-២០០៤ របស់ឈ្មោះ សុខ ឃឿន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បដិសេធសាលក្រមរដ្ឋប្បវេណីលេខៈ ៣៣ ចុះថ្ងៃទី២៤-០៥-២០០៤ និង សាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខៈ ១៣ ចុះថ្ងៃទី០៤-០៣-២០០៤ របស់តុលាការខេត្តកំពង់ស្ពឺចោលជាអសារបង់ ។

៣ - បង្គាប់ឱ្យឈ្មោះ អ៊ុង សារួន និង ប្រពន្ធឈ្មោះទិត ស៊ីណាត សងប្រាក់ដើមចំនួន ៧.០០០ដុល្លាអាមេរិក ( ប្រាំពីរពាន់ដុល្លាអាមេរិក ) ការប្រាក់ ៥% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី០៤-០៩-២០០៤ រហូតដល់ថ្ងៃទូទាត់បំណុលរួច និង ជម្ងឺចិត្តចំនួន ៥.០០០ដុល្លាអាមេរិក ( ប្រាំពាន់ដុល្លាអាមេរិក )ឱ្យទៅដើមចោទឈ្មោះ សុខ ឃឿន ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើសពីនេះបដិសេធចោល ។

- បើគ្មានប្រាក់សងទេត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងធានាសំណង.

- បើរឹងរូសត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ស្តីពី វិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៤ - កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛០០ ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០៛០០ និង អាជ្ញាធរតុលាការចំនួន ៥.០០០៛០០ ។ នៅពេលសាលដីកានេះ

ចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១៣.០០០រ០០ ទៅឱ្យដើមចោទវិញ និង បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ ១% លើប្រាក់ដើម. ការប្រាក់ និង ជម្ងឺចិត្ត ។

៥ - សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី៣១-០៨-២០០៤ ចំពោះមុខគូក្តី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០៨-០៩-២០០៤កំបាំងមុខគូក្តីតែចាត់ទុកជាចំពោះមុខបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ ៣៩២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះ អ៊ុង សារូន និង ប្រពន្ធឈ្មោះ ទិត ស៊ីណាត បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល និង បណ្តឹងសាទុក្ខលេខៈ ៧៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ សុខ ឃឿន បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣ នៃសាលដីការបស់សាលាឧទ្ធរណ៍ ។

បានឃើញសារណាការពាររបស់ឈ្មោះ អ៊ុង សារូន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសារណារឆ្លើយតបរបស់ឈ្មោះ សុខ ឃឿន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់លោក អ៊ុង សារូន និង បណ្តឹងសាទុក្ខរបស់អ្នកស្រី សុខ ឃឿន ស្ថិតក្នុងកំណត់ច្បាប់ គម្បីលើកយកមកពិចារណា ។

សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ សុខ ឃឿន ។

អ្នកស្រី ទិត ស៊ីណាប្រពន្ធឈ្មោះ អ៊ុង សារូន បានឆ្លើយថា : ព្រោះសាលាឧទ្ធរណ៍បានសំរេចដោយអយុត្តិធម៌ដោយខ្លួនបានបង់ការប្រាក់ខុសច្បាប់ឱ្យគាត់បានច្រើនណាស់ហើយដែរនេះគឺជារឿងខ្ចីលុយចងការប្រាក់ទេ មិនមែនជាការទិញលក់ផ្ទះទេ ខ្លួនបានទៅខ្ចីប្រាក់គាត់ចំនួន មួយម៉ឺនដុល្លាអាមេរិក តែអ្នកស្រី សុខ ឃឿន បានឱ្យខ្លួនជាពីរដំណាក់កាលដោយសរុបទាំងពីរលើកនេះខ្លួនបានទទួលប្រាក់តែ ប្រាំបីពាន់បួនរយដុល្លាអាមេរិក ប៉ុណ្ណោះ ចំពោះប្រាក់ចំនួន មួយពាន់ប្រាំមួយរយ នៅគាត់ដកថ្លៃទឹកតែ និង ការប្រាក់ ហើយខ្លួនបានទៅខ្ចីគាត់ចំនួន ពីរពាន់បន្ថែមទៀតតែនៅពេលនេះក៏ទទួលបានមិនគ្រប់ដែរ គឺ បានតែមួយពាន់ប្រាំពីររយ គឺគាត់ដកយក បីរយ ថ្លៃទឹកតែដែរ ដូច្នេះសរុបប្រាក់ទាំងអស់មានចំនួនតែ មួយម៉ឺនមួយរយ ប៉ុណ្ណោះ ។

ការប្រគល់លុយនេះ គឺ គាត់បានកត់លេខលុយត្រឹមត្រូវណាស់ ដោយមានឯកសារនៅក្នុងសំណុំរឿងស្រាប់ ។

សំណូមពរ : សុំកាត់យកការប្រាក់ខុសច្បាប់មកបញ្ចូលជាប្រាក់ដើមវិញ ហើយសុំបដិសេធសាលដីកា របស់សាលាឧទ្ធរណ៍ចោលទាំងមូល ។

មេធាវីលោក ទូ ចន្ថា ការពារឱ្យលោក អ៊ុង សារូន បានធ្វើសេចក្តីសន្និដ្ឋានថា :

កាលពីនៅតុលាការខេត្តអ្នកស្រី សុខ យឿន បានប្តឹងទាមទារសុំសិទ្ធិគ្រប់គ្រងលើដី និង សុំឱ្យកូនក្តីរបស់ខ្លួនចុះចេញពីផ្ទះ ការសំរេចរបស់តុលាការខេត្តក៏បានសំរេចតាមបណ្តឹងរបស់ដើមចោទដោយឱ្យកូនក្តីរបស់ខ្លួនចុះចេញពីផ្ទះដែលមានភាពអយុត្តិធម៌ណាស់ ទើបកូនក្តីរបស់ខ្លួនប្តឹងឧទ្ធរណ៍សាលក្រមរបស់តុលាការខេត្តមិនទាន់ចូលជាស្ថាពរ គាត់ក៏នាំគ្នាទៅដេញអ្នកស្រី ទិត ស៊ីណាត និង គ្រួសាររបស់កូនក្តីខ្លួនឱ្យចុះចេញ ដែលត្រង់នេះល្មើសនឹងមាត្រា ១៩៧ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ។

កាលពីនៅសាលាឧទ្ធរណ៍ពេលសវនាការដើមចោទមិនបានចូលរួមសវនាការទេ សាលាឧទ្ធរណ៍បង្វែបណ្តឹងមកជាកិច្ចសន្យាខ្ចីប្រាក់ទៅវិញដែលការសំរេចនេះមិនទាន់មានពាក្យបណ្តឹងទេ ដូច្នេះសាលាឧទ្ធរណ៍បានសំរេចខុសពីកម្មវត្ថុបណ្តឹងហើយ ។ សូមឯកឧត្តម មេត្តាសំរេចលើចំណុចនេះឱ្យបានច្បាស់ ។

ការលក់ផ្ទះគ្នាបានដាក់តំលៃពិតប្រាកដទេ ដែលមានឯកសារនៅក្នុងសំណុំរឿងស្រាប់ ដូច្នេះនេះបញ្ជាក់ឱ្យឃើញថាអ្នកស្រី សុខ យឿន មិនអាចក្លាយជាម្ចាស់កម្មសិទ្ធិបានឡើយហើយផ្ទុយនឹងមាត្រា ១៧៧ នៃច្បាប់ភូមិបាល

សំណូមពរ : សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងមូល ហើយសុំបញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីឱ្យសាលាឧទ្ធរណ៍សំរេចជាថ្មីឡើងវិញ ។

មេធាវីលោក កែវ យ៉ា ការពារឱ្យអ្នកស្រី សុខ យឿន បានធ្វើសេចក្តីសន្និដ្ឋានថា :

ជាដំបូងខ្លួនសុំអនុញ្ញាតឯកឧត្តម សួរទៅអ្នកស្រី ទិត ស៊ីណាត ថា តើអ្នកស្រី បានអះអាងថាបានបង់ការប្រាក់មួយខែ ៥០០ និង ៦០០ មានហេតុផល ឬ ភស្តុតាងមកបញ្ជាក់ដែរឬទេ ?

តាមពាក្យបណ្តឹងនៅតុលាការថ្នាក់ក្រោមកូនក្តីរបស់ខ្លួនបានដាក់ប្តឹងទាមទារផ្ទះ និង ដីពិតមែន តែក្រោយមកគឺក៏បានដាក់បណ្តឹងប្តឹងទាមទារប្រាក់វិញ ហើយក៏សាលាឧទ្ធរណ៍បានសំរេចតែលើបណ្តឹងទាមទារប្រាក់តែប៉ុណ្ណោះ ដូច្នេះមេធាវីចុងចម្លើយបានសន្និដ្ឋានផ្ទុយពីសេចក្តីសំរេចហើយ ។

តាមពិតកិច្ចសន្យាទិញ-លក់ គឺ ជាកិច្ចសន្យាមួយការពារទៅថ្ងៃក្រោយក្នុងករណីដែលគាត់ប្រកែក ឬ គ្មានប្រាក់សងវិញតែប៉ុណ្ណោះ ។ អ្នកស្រី សុខ យឿន បានទទួលការប្រាក់ ប្រាំរយក្នុងមួយខែ មែនដោយសរុបប្រាក់ទាំងអស់បាន ប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក តែការប្រាក់នេះគាត់ក៏មិនបានធ្វើលិខិតស្នាមអ្វីដែរ នេះបញ្ជាក់ពីភាពស្មោះត្រង់របស់គាត់ហើយ ដោយគាត់បានទទួលស្គាល់ ដោយបានកាត់ការប្រាក់នេះទៀត ឃើញថា ប្រាក់ដើមនៅសល់តែ ប្រាំពាន់ប្រាំរយ តែប៉ុណ្ណោះ ។

តាងនាមខ្លួនជាមេធាវី ហើយជាអ្នកតំណាងឱ្យអ្នកស្រី សុខ យឿន ខ្លួនសុំសំណូមពរដូចខាងក្រោម ÷

សុំកែប្រែដោយកាត់បន្ថយប្រាក់ពី ប្រាំពីរពាន់ដុល្លា មកនៅតែ ប្រាំពាន់ វិញ និង សំណងជម្ងឺចិត្តមាន ប្រាំពាន់ដុល្លា មកត្រឹមតែ បីពាន់ដុល្លា វិញ ដើម្បីបញ្ចប់រឿងក្តីត្រឹមនេះជៀសវាងការអូសបន្លាយពេលវេលា ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអាយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ សារណារបស់ដើមចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា : បណ្តឹងសាទុក្ខលេខៈ ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់លោក អ៊ុង សារួន និង អ្នកស្រី ទិត្យ ស៊ីណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានដោយតាម មាត្រា ១៤ នៃច្បាប់ស្តីពីការ ចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សំរេចឱ្យចុងចម្លើយសងប្រាក់ដើមទៅដើមចោទចំនួន ៧.០០០ដុល្លាអាមេរិក ដោយសំអាងចុងចម្លើយបានខ្ចីប្រាក់ចំនួន ១២.០០០ដុល្លា ហើយចុងចម្លើយបានឱ្យការប្រាក់ខុសច្បាប់ចំនួន ៥.០០០ដុល្លា ហើយនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា តាមលិខិតទទួលប្រាក់ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ និង លិខិតទទួលប្រាក់ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០២ ចំនួនប្រាក់ដែលដើមចោទប្រគល់ឱ្យចុងចម្លើយមានត្រឹមតែ ៨២ សន្លឹក ស្មើនឹងចំនួន ៨.២០០ដុល្លាអាមេរិក ដូចការអះអាងរបស់ចុងចម្លើយដែរ ។

យល់ឃើញថា : ការដែលមេធាវីដើមចោទ សុំឱ្យតុលាការកំពូល បន្ថយប្រាក់សំណង និង ជម្ងឺចិត្តឱ្យដើមចោទនោះ តុលាការកំពូល ដែលជំនុំជំរះអង្គច្បាប់ពុំអាចពិចារណាបានទេ ។

យល់ឃើញថា : ដើមចោទបានធ្វើសារណាជូនមក តុលាការកំពូល រួចហើយ ប៉ុន្តែអ្នកស្រីពុំបានចូលរួមនាពេលសវនាការនេះទេ ឯមេធាវីអ្នកស្រីបានចូលរួម ដូចនេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខអ្នកស្រី ចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខៈ ១៤៤ " ឈ " ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី ចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខៈ ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីការដ្ឋប្បវេណី លេខៈ ១៤៤ " ឈ " ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខៈ ១០២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលដើមចោទ បានបង់ជូសនៅតុលាការកំពូល គឺ ÷

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

៥ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ។